01481404



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-May-2017, 13:20
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧**

**ម៉ោង ១៣:៣៣នាទី**

**សវនាការលើកទី៤៩៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រមនិលណុន  ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង

លោក រ៉ូជ័ រ ហ្វីលីព*(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកនីកូឡាស គូមជែន
*(Mr.Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទនួន ជា៖**

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ*(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍(*Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្មួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន(ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[១៣:៣៣:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការដាក់បង្ហាញឯកសារគន្លឹះ ដោយក្រុមមេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងអង្គហេតុតួនាទីរបស់ជនជាប់ចោទ។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការរសៀលនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន លើកលែងតែលោក វ៉ិចទ័រ កូប៉េ មេធាវីអន្តរជាតិការពារក្តីឲ្យលោក នួន ជា ដែលបានជូនដំណឹងមកថា នឹងអវត្តមាននៅសវនាការរសៀលនេះដោយមូលហេតុសុខភាព។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណកញ្ញា ជា ស៊ីវហ័ង។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៥ ខែ មករា ឆ្នាំ២០១៧ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាពឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និង ដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង មានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០១៧។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំ

ការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការ:ឈឺចង្កេះពេលអង្គុយ និងវិលមុខ បើសិនជាអង្គុយយូរ និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួលតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយ:ឧបករណ៍សោតទស្សន៍សម្រាប់រយ:ពេលសវនាការពេញមួយរសៀលនេះ។

ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់រសៀលនេះ។

ហើយ បាទជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីធ្វើការឆ្លើយតបទៅនឹងបណ្ដាឯកសារគន្លឹះដែលដាក់បង្ហាញដោយក្រុមសហមេធាវីការពារក្ដី ខៀវ សំផន កាលពីម្សិលមិញ។

[១៣:៣៦:៣៩]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ <>ជម្រាបសួរលោក លោកស្រីចៅក្រម។ កាលពីម្សិលមិញមេធាវីការពារក្ដី ខៀវ សំផន បានចំណាយពេលយ៉ាងច្រើននិយាយអំពីគោលនយោបាយរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ហើយបាន<>ការពារដល់គោលនយោបាយទាំងអស់នេះ។ ខ្ញុំគិតថា វាជាការសមស្របមួយដែលមេធាវីការពារក្ដី ខៀវ សំផន លើកឡើងអំពីចំណុចទាំងអស់នេះ ព្រោះ ខៀវ សំផន បាន<រួមចំណែកក្នុងការបង្កើត និងផ្សព្វផ្សាយ>គោលនយោបាយទាំងអស់នេះ នៅពេលដែលគាត់ធ្វើ<សុន្ទរកថា និងវគ្គ>បណ្ដុះបណ្ដាល<>កម្មាភិបាល<នានានោះ>។ ការយល់ខុសមួយដែលមេធាវីការពារក្ដីបានបង្ហាញគឺថា ពួកគេបាន<លើកយកទឡ្ហីករណ៍ថារបប>ហ្នឹង<ពុំ>មានចេតនា<ធ្វើឲ្យមនុស្សជួបគ្រោះទុរភិក្ស ដាច់បាយ ព្រោះតែមានបំណងកសាង>សេដ្ឋកិច្ច <ដោយសង្ឃឹមថានឹងបង្កើនទិន្នផលស្រូវ>។<ខាងព្រះរាជអាជ្ញាមិនដែលលើកយកករណីអ្នកដែលដាច់ពោះស្លាប់ថា គោល

បំណងប្រកបដោយមនសិការរបស់ថ្នាក់ដឹកនាំខ្មែរក្រហមឡើយ>។ គោលជំហររបស់យើងគឺថា<ថ្នាក់ដឹកនាំទាំងនេះ ធ្វើមិនដឹងមិនឮ> ជាពិសេសចំពោះការឈឺចាប់របស់ប្រជាជន គឺថាពួកគេប្រព្រឹត្តចំពោះប្រជាជន<ដូចសត្វធាតុ> គឺគេប្រើប្រាស់សិទ្ធិជាម្ចាស់ គឺគេមិនចង់ឲ្យគោក្របី<>ហ្នឹង<ងាប់>ទេ ប៉ុន្តែគេ<មិនដែលខ្វល់ខ្វាយពីសេចក្តីស្លាប់របស់សត្វទាំងនោះ ក៏ដូចជាកូនៗរបស់គេដែរ>។ <នេះមិនខុសគ្នាពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលតម្កល់ជីវិត និងកិត្តិស័ព្ទរបស់ថ្នាក់ដឹកនាំនៃរបបនោះ។ ដោយគេជឿថាគេទាំងអស់គ្នាជាអ្នកចេញមុខចេញមាត់ក្នុងចលនាបដិវត្តន៍ទៅលើឆាកអន្តរជាតិ ដែលហួសឆ្ងាយពីអត្ថប្រយោជន៍របស់ប្រជាជនកម្ពុជា ជំរុញឲ្យ>ប្រជាជន<ធ្លាក់ចូលទៅក្នុងទុរភិក្ស ដាច់ពោះ និង>ក្លាយទៅជាទាសករ។

[១៣:៣៨:៣៧]

មេធាវីការពារក្តីបានលើកអំពីចំណុចមួយទៀតដែលនិយាយថា៖ “មជ្ឈិមមិន<មានសមត្ថភាព> គ្រប់គ្រង<ទេ>ព្រោះលេខាភូមិភាគ<ដូច>ជាស្តេចត្រាញ់<ទៅហើយ>” ដោយបានដកស្រង់សម្តី ហ្វីលីព ស្សូត។ ប៉ុន្តែប្រសិនបើយើងមើលនៅក្នុងសៀវទាំងមូលរបស់ ហ្វីលីព ស្សូត <វិញ> ក៏ដូចជាសក្ខីកម្មរបស់គាត់នៅក្នុងសំណុំរឿង០០២/០១ គាត់មិនបាននិយាយថា មជ្ឈិម<មិន>គ្រប់គ្រងទៅលើគោលនយោបាយនោះ<ឯណា។ អ្វីដែលគាត់និយាយនោះ> គឺនៅទំព័រ<ជាភាសាអង់គ្លេសលេខ> 00396491, <ភាសា>បារាំងមានលេខ 00639820 គឺមិនមានភាសាខ្មែរនោះទេ គឺនិយាយថា៖ “លេខាភូមិភាគដែលមេដឹកនាំផងនោះ <ក្រោយមក> ក្នុងតួនាទីជាស្តេចត្រាញ់តាមខេត្ត គឺស្មោះត្រង់ជាមួយមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា<ណាស់។” ដូច្នេះហើយ ពេលដែលគាត់ពិភាក្សាជាមួយពួកគេអំពីខ្សែបណ្តោយការងារ ក៏ដូចជាប្រធានតំបន់ ឬចៅហ្វាយខេត្តតាមខេត្តនានា> គឺគាត់បានបញ្ជាក់ច្បាស់នៅក្នុងសៀវភៅរបស់គាត់ ក៏ដូចជានៅក្នុងសក្ខីកម្មរបស់គាត់ថា មេភូមិភាគ<ទាំងនេះ>គោរព<ធ្វើតាមអ្នកដឹកនាំរបស់មជ្ឈិម>។ <តាមពិតទៅ> រដ្ឋមនុញ្ញ ឬក៏លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាបានបញ្ជាក់ច្បាស់ថា តើការបញ្ជាហ្នឹងវាមានលក្ខណៈយ៉ាងម៉េច។ នៅក្នុងមាត្រា២៧ <>និយាយអំពីតួនាទីរបស់កងទ័ព<>។ <ដោយខ្ញុំគិតថាមានកំហុសក្នុងការវាយអត្ថបទ ហើយភាសាអង់គ្លេស ដូចជាមិនសូវត្រូវវេយ្យាករណ៍ផង មើលមិនយល់ អ៊ីចឹង>ខ្ញុំ<គិតថា>សហការីខ្ញុំអាន<ឯកសារដើម មាត្រា ២៧ ជាភាសាខ្មែរ> ។

**កញ្ញា សុង ឆវ័ន្ត៖**

ខ្ញុំបាន ខ្ញុំដកស្រង់ចេញពីឯកសារ E3/--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាល់ទាន់! អញ្ជើញលោកស្រី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោសលោកសហព្រះរាជអាជ្ញា ខ្ញុំចង់ដឹងថាតើលោកសហព្រះរាជអាជ្ញាយោងទៅលើឯកសារមួយណាដែរ? សូមឱ្យជួយផ្តល់លេខឯកសារហ្នឹងផង។ <តើនៅក្នុង>សៀវភៅរបស់ហ្វីលីព ស្សូត ឬក៏ជាសៀវភៅណា ឬក៏<តាម>ERN <ដែលលោកផ្តល់ដល់ពួកយើង ឬក៏ដកស្រង់ចេញពី>ឯកសារ<ផ្សេងមួយទៀត? ព្រោះខ្ញុំជឿថាក្នុង>ការឆ្លើយតប គឺមិន<>មានដាក់ឯកសារថ្មី<ទេ>។ <ដោយហេតុថាព្រះរាជអាជ្ញាបានស្នើសុំលះបង់សិទ្ធិក្នុងការដាក់បង្ហាញឯកសារលើបញ្ហានេះ។>អ៊ីចឹងខ្ញុំចង់ដឹង<ឱ្យច្បាស់ថា>ឯកសារហ្នឹង <និងចង់ដឹងថាតើព្រះរាជអាជ្ញាដកស្រង់យកមកពីឯកសារណាមួយ។>

[១៣:៤១:១៨]

**លោក នីកូឡាស គូមជែន៖**

សហការីខ្ញុំនឹងផ្តល់ឯកសារ គឺE3/214។ ខ្ញុំសូមបញ្ជាក់ថា <ជំហររបស់>មេធាវីការពារក្តី<គឺចង់លើកពីជាឯកសារ>ថ្មី<ទាំងស្រុងតែម្តង គឺថាយើងខ្ញុំមិនអាចបង្ហាញឯកសារថ្មីដែលទាស់ទៅនឹង>ទឡ្ហីករណ៍របស់មេធាវីការពារក្តីនោះទេ<។ ក្នុងសវនាការឯកសារ> មេធាវីការពារក្តី ខៀវ សំផន <មិន>បានបង្ហាញនូវឯកសារ<ទេ ពួកគេបែរជាលើកឯកសារ>ថ្មី<វិញ ក្នុងការឆ្លើយតបរបស់ខ្លួនអ៊ីចឹង> យើងក៏គ្រោងនឹងបង្ហាញឯកសារថ្មីដូចគ្នានោះដែរ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំចង់ឱ្យសហព្រះរាជអាជ្ញានិយាយច្បាស់ ថាឯកសារថ្មីណាដែលយើងបានប្រើប្រាស់<ក្នុងការឆ្លើយតប>នោះ? ពេលដែលយើងឆ្លើយតបនោះ <>គឺថាយើងតែងតែប្រើប្រាស់ឯកសារដែលសហព្រះរាជអាជ្ញាបានប្រើទេ យើងមិនដែលយកឯកសារថ្មីយកមកឆ្លើយទេ។ អ៊ីចឹងលោកលើកឡើងហ្នឹង គឺមិនត្រឹមត្រូវទេ ថាអ្វីដែលយើងធ្វើការពីអតីតកាលនុ៎ង ពេលដែលយើងឆ្លើយតបទៅនឹងឯកសាររបស់សហព្រះរាជអាជ្ញានោះ។ អ៊ីចឹងថ្ងៃនេះសហព្រះរាជអាជ្ញាអត់មានបានប្រាប់យើងសោះថា ខ្លួនចង់ប្រើប្រាស់ឯកសារណាខ្លះ <សម្រាប់សវនាការថ្ងៃនេះឡើយ>។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៣:៤២:២៤]

**លោក នីកូឡាស គូមជែន៖**

<លោក លោកស្រីចៅក្រម> ខ្ញុំមិនទាន់នឹកឃើញនៅឡើយនោះទេ <ព្រោះថាមេធាវីបានសួរខ្ញុំភ្លាមៗតែម្តង>។ <យើងមិនមានពេលដូច>មេធាវីការពារក្តី<នោះទេ ដែលពួកគេមានពេលវេលាចន្លោះ តែខុសពីពួកគេ ខាងយើងខ្ញុំត្រូវធ្វើបទបង្ហាញឯកសារនៅថ្ងៃបន្ទាប់។ ដូច្នេះយើងត្រូវចំណាយពេលវេលាពេលព្រឹក ហើយពេលល្ងាចត្រូវរៀបចំឯការជាបន្តទៀត។ ខ្ញុំមិនដឹងថាហេតុអ្វីបានជាមេធាវីការពារក្តីត្រូវការឯកសារនោះទេ។ ពេលអានសម្រង់ ខ្ញុំនឹងបញ្ជាក់ជាមួយដែរហើយ>។

**កញ្ញា អង់តា ហ៊ីសសេះ៖**

លោកប្រធាន ហេតុផលដែលសហព្រះរាជអាជ្ញាមិនមានឯកសារយោងនៃចម្លើយដែលយើងបាន<ផ្តល់ដោយផ្អែកលើ>ឯកសារ<នានានោះ>ដោយសារតែ<គាត់មិនមានសោះ។ រាល់ពេលដែលយើងឆ្លើយតបទៅកាន់ព្រះរាជអាជ្ញា យើងបាន>ប្រើប្រាស់ឯកសារ<ដែលខាងព្រះរាជអាជ្ញាបានដាក់បង្ហាញ>តែប៉ុណ្ណោះ<។ ពាក់ព័ន្ធនឹងរយៈពេលខុសគ្នាមួយថ្ងៃដើម្បីត្រៀមខ្លួនឆ្លើយតបរបស់យើងវិញ គឺថានៅពេលមួយដែលការឆ្លើយតបត្រូវបានអនុញ្ញាតឲ្យធ្វើក្នុងពេលរសៀលបន្ទាប់ពីខាងព្រះរាជអាជ្ញាបានបង្ហាញឯកសារគោលរបស់ពួកគេ។>ហើយឥឡូវនេះគាត់<ព្យាយាមលៃលកមិនចង់>បង្ហាញឯក-សារនៅក្នុង<ផ្នែក>នេះ។ ហើយគាត់<ធ្វើដូច្នេះគឺមិនត្រឹមត្រូវទេ>។ ខ្ញុំសូមជំទាស់ទៅនឹង<ការដាក់បង្ហាញឯកសារថ្មីៗទៀត។ បើតាម>គោលការណ៍<គឺថាយើងឆ្លើយតបទៅនឹងឯកសារទាំងឡាយណាដែលបានដាក់បង្ហាញនៅចំពោះមុខភាគីទាំងអស់ដូចដែលយើធ្លាប់ធ្វើ>តែប៉ុណ្ណោះ<>។ <ខ្ញុំមិនដឹងថាហេតុអ្វីបានជាគាត់មានសិទ្ធិធ្វើដូច្នេះនៅថ្ងៃនេះ ដែលយើងមិនដែលមានសោះពីមុន>។

[១៣:៤៤:០៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវី តើលោកស្រីយល់ស្របទេ នៅក្នុងបទបង្ហាញរបស់លោកស្រី គឺ<លោកស្រីបង្ហាញ>ហួសពីឯកសារធម្មតា ដែល<បង្ហាញពីតួនាទីរបស់ជនជាប់ចោទដែរឬទេ?>។ លោកស្រី<ចាប់ផ្តើមជជែកវែកញែកការពារក្តី ហើយយើងចាំស្តាប់លោកស្រីដោយមិនបានរំខានលោកស្រីឡើយ។ ក្រោយមកលោកស្រីនិយាយអំពីគោលនយោបាយ ហើយផ្តោតលើ>តួនាទីរបស់ជនជាប់ចោទ<ដែលកាន់តែចូលទៅចំណុចចង្អៀត ហើយខ្ញុំគិត>ថាលោកស្រី <ខ្លួនឯងផ្ទាល់ក៏ទទួលស្គាល់ថា នៅពេលដែលចាប់

ផ្ដើម លោកស្រីបានរំឭកដល់យើងថា៖“ខ្ញុំនឹងចូលទៅដល់ចំណុចជាក់លាក់ស្ដីអំពី>តួនាទីរបស់ជនជាប់ចោទបន្តទៅទៀត”។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំមិនយល់ស្របជាមួយលោកស្រីចៅក្រម ហ្វេនស៍ ទេ <ដែល>ថាខ្ញុំធ្វើហួសក្របខ័ណ្ឌនៃវគ្គសវនាការយើងនោះ។ ខ្ញុំបានរំឭកនៅដើមសវនាការហើយថានៅពេលដែលយើងចង់បង្ហាញឯកសារពាក់ព័ន្ធទៅនឹងគោលនយោបាយនោះ គឺអង្គជំនុំជម្រះខ្លួនឯងទេដែលនិយាយថា ពេលដែលយើងបង្ហាញឯកសារពាក់ព័ន្ធនឹងតួនាទីហ្នឹង យើងអាចបង្ហាញឯកសារពាក់ព័ន្ធនឹងគោលនយោបាយបាន។ អ៊ីចឹងខ្ញុំ <គ្រាន់តែ>ធ្វើតាមសេចក្ដីណែនាំរបស់អង្គជំនុំជម្រះទេ<។ ខ្ញុំចាំបានថា> ខ្ញុំ<>យោងទៅលើ<ឯក-សារ>ពាក់ព័ន្ធទៅនឹងទីតាំងការដ្ឋាននោះ<ខ្ញុំភ្លេចកាលបរិច្ឆេទបាត់ទៅហើយ>។ ពេលនោះ ពេលដែល <សហភាតារបស់ខ្ញុំ លោកមេធាវី> វែកគែន គាត់ចង់ប្រើឯកសារចង់បង្ហាញឯកសារពាក់ព័ន្ធនឹងគោលនយោបាយ ពេលនុ៎ងអង្គជំនុំជម្រះបានប្រាប់មេធាវី វែកគែន <>ក៏ដូចជាភាគីថា ចាំក្រោយទៅ កុំៗធ្វើពេលហ្នឹងអី <ហើយបង្គាប់ឲ្យផ្ដោតការយកចិត្តទុកដាក់លើផ្នែកការដ្ឋានទៅបានហើយ រឿងគោលនយោបាយទូទៅ គួរតែទុកបង្ហាញសម្រាប់វគ្គស្ដីពី>តួនាទីរបស់ជនជាប់ចោទ<វិញ>។ អ៊ីចឹងខ្ញុំមិនមែនធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់អីទេ ខ្ញុំមិនចង់ចំណាយពេលច្រើនទេ ហើយខ្ញុំបានចំណាយពេលម្សិលមិញច្រើន ដើម្បីដកស្រង់ឯកសារ ខ្ញុំដឹងថា វាធុញទ្រាន់ណាស់នៅពេលដែលយើងធ្វើការងារបែបហ្នឹងនោះ។ ហើយខ្ញុំព្យាយាមបង្ហាញឲ្យបានច្បាស់ អ៊ីចឹងខ្ញុំយល់ថាមិន អង្គជំនុំជម្រះមិនគួរណាអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាធ្វើហួសពីអ្វីដែលអង្គជំនុំជម្រះបានកំណត់នោះទេ។ ហើយគាត់ធ្វើបែបហ្នឹងគឺៗ វាខុសហើយ ភាគីអត់អាចធ្វើអ៊ីចឹងបានទេ ខ្ញុំក៏មិនដឹងថារបៀបអ៊ីចឹងមកពីមុនមកដែរ។ <ខ្ញុំនៅតែជំទាស់ដដែល។>

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមបញ្ជាក់ថា ឯកសារដែលយើងខ្ញុំធ្វើគឺមិនមែនជាឯកសារថ្មីនោះទេ គឺជាឯកសារដែលមាននៅក្នុងសំណុំរឿងស្រាប់រួចទៅហើយ <ដែលយើងបានយោងកន្លងមក ប៉ុន្តែ ឯកសារទាំងនេះជាឯក-សារសម្រាប់ឆ្លើយតប។>

[១៣:៤៦:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៣:៥១:០១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីធ្វើការសម្រេចដោះស្រាយបញ្ហាដែលមានការខ្វែងគ្នារវាងសហព្រះរាជអាជ្ញា ជាមួយនឹងមេធាវីការពារក្តីលោក ខៀវ សំផន លើកឡើងបញ្ហាអម្បាញ់មិញនេះ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ មេធាវីការពារក្តីជំទាស់ទៅនឹងការប្រើប្រាស់ដោយសហព្រះរាជអាជ្ញានូវឯកសារផ្សេង ក្រៅពីឯកសារដែលមេធាវីការពារក្តី ខៀវ សំផន បានបង្ហាញក្នុងសវនាការ ស្តីពីឯកសារគន្លឹះ។ <តែយ៉ាងណាក្តី> បើមេធាវីការពារក្តីយោងទៅលើបទពិសោធន៍ ឬក៏ទម្លាប់ពីចាស់នោះ គឺអង្គជំនុំជម្រះមិនដែលបានច្រានចោលថា មិនឱ្យប្រើប្រាស់ឯកសារផ្សេងយកមកឆ្លើយតបទៅនឹងឯកសារបង្ហាញដោយមេធាវីការពារក្តីនោះទេ។ ដូច្នេះ ក្នុងន័យនេះ ការជំទាស់នេះមិនមានមូលដ្ឋាន<ខ្លាំងនោះ>ទេ។ ពិតណាស់ថា ក្នុងទម្លាប់អនុវត្តពីមុនមក គឺភាគីដែលចង់ប្រើប្រាស់ឯកសារហ្នឹង គួរតែប្រាប់ភាគីផ្សេងជាមុន។ ក៏ប៉ុន្តែដើម្បីឱ្យមានសមធម៌នោះ គឺថារយៈពេល<កំណត់>នៃការឆ្លើយតបទៅនឹងការបង្ហាញឯកសារ<គន្លឹះ>របស់មេធាវីការពារក្តី ខៀវ សំផន <>គឺ<មានរយៈពេលខ្លី។ ពេលវេលានោះគឺនៅ>រសៀលម្សិលមិញ ហើយនិងព្រឹកថ្ងៃនេះ។ អ៊ីចឹងសហព្រះរាជអាជ្ញា គាត់ពិបាកក្នុងការធ្វើបញ្ជីឯកសារដើម្បីផ្តល់ជូនមេធាវីការពារក្តី ខៀវ សំផន <ឱ្យបានមុនហ្នឹង>។ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយនោះ សហព្រះរាជអាជ្ញា គាត់អាចយកឯកសារផ្សេង យកមកឆ្លើយតបទៅនឹងឯកសារបាន ហើយពេលនុ៎ង មេធាវីការពារក្តីហ្នឹង ក៏អាចធ្វើមតិអត្ថាធិប្បាយទៅលើឯកសារបន្ថែម ដែលសហព្រះរាជអាជ្ញាយកមកប្រើដើម្បីឆ្លើយតបផងដែរ។ អ៊ីចឹង វាអាស្រ័យទៅលើពេលវេលាដែលសហព្រះរាជអាជ្ញាគាត់ឆ្លើយ ថាតើគាត់ចប់នៅពេលណានោះ ហើយបើមេធាវីការពារក្តីចង់ធ្វើមតិអត្ថាធិប្បាយហ្នឹង អាចធ្វើបាននៅរសៀលនេះនោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តទៀត លោកសហព្រះរាជអាជ្ញាអន្តរជាតិ។

[១៣:៥៣:៣៦]

**កញ្ញា សុង ឆវ័ន្តៈ**

ចាស លោកប្រធាន ខាងសហព្រះរាជអាជ្ញាដកស្រង់យកពីឯកសារ E3/214 នៅត្រង់ERN ជាភាសាខ្មែរ 0005303344 និងERN ជាភាសាអង់គ្លេស 00184046, ជាភាសាបារាំង 00292933។ នេះជាលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា នៅត្រង់ជំពូកទី៦ អំពីកងទ័ពបដិវត្ត ត្រង់មាត្រា២៧។ ខ្ញុំដកស្រង់ ៖ "កងទ័ពបដិវត្តកម្ពុជាទាំងបីប្រភេទ ស្រួច តំបន់ ឈ្លប ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ដាច់មុខ ដាច់ខាត និងគ្រប់ផ្នែករបស់បក្សកុម្មុយនីស្តកម្ពុជា។" បញ្ចប់ការដកស្រង់។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំចង់ធ្វើសំណូមពរខ្លីមួយ ទាក់ទងទៅនឹងការដាក់ឯកសារថ្មីនេះ។ ដូចលោកចៅក្រម ឡាវ៉ែន៍ គាត់បានមានប្រសាសន៍អម្បាញ់មិញ ការដាក់ឯកសារថ្មីគួរតែផ្ដល់ពេលវេលា២៤ម៉ោងសម្រាប់ឲ្យភាគីតាមដានទៅលើឯកសារទាំងនោះ។ ដូច្នេះ បើថារយៈពេលឥឡូវនេះ វាខ្លីសម្រាប់សហព្រះរាជអាជ្ញាក្នុងការដាក់ឯកសារ គួរតែមានពេលវេលាឥឡូវសម្រាប់ឲ្យដំណឹងមកភាគីវិញថាតើឯកសារណាខ្លះ ដែលសហព្រះរាជអាជ្ញាមានបំណងចង់ដាក់តាំង ដើម្បីឲ្យយើងមានឱកាសពិនិត្យទៅលើឯកសារនោះ ត្រៀមដើម្បីឆ្លើយតបផង។ បើមិនអ៊ីចឹងទេ វាអាចមានការលំបាកសម្រាប់យើងក្នុងការឆ្លើយតបទៅសហព្រះរាជអាជ្ញាវិញ ដែលតាមជាក់ស្ដែងយើងឃើញហើយឯកសារមួយៗវាមានវែង ហើយច្រើនទំព័រ ដែលវាពិបាកក្នុងការពិនិត្យផង។ អ៊ីចឹងសូមឲ្យផ្ដល់អាចឈ្មោះឯកសារ និង ទីតាំងដែលត្រូវដកស្រង់ជាក់លាក់ផងមក បើសិនជាអាចធ្វើបាន។បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ត្រឹមត្រូវហើយ អាហ្នឹងធម្មតាយើងការដាក់បង្ហាញឯកសារ គឺទាំងឯកសារគន្លឹះ ទាំងឯកសារទូទៅដែលជាឯកសារភស្តុតាង យើងត្រូវដាក់លេខសម្គាល់ឯកសារ ហើយនិងទំព័រឯកសារ ដោយបញ្ជាក់លេខ ERN ទាំងបីភាសា ឬក៏យ៉ាងហោចណាស់ពីរភាសាដែលប្រើប្រាស់នៅក្នុងតុលាការនេះ។ ហ្នឹងបញ្ហាទី១។

[១៣:៥៦:០៦]

បញ្ហាទី២ យើងបានឯកភាពនៅផ្ទៃក្នុងអង្គជំនុំជម្រះបានកំណត់រួចហើយអម្បាញ់មិញនេះ។ ទី១ បញ្ជាក់ថា ឯកសារដែលបានប្រើប្រាស់នៅទីនេះ អង្គជំនុំជម្រះអនុញ្ញាត -- មិនអនុញ្ញាតឲ្យប្រើប្រាស់ឯកសារថ្មីទេ គឺឯកសារដែលមាននៅក្នុងសំណុំរឿងចំណាត់ថ្នាក់ E3 រួចហើយ។ ហើយបញ្ហា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឆ្លើយតបរបស់ភាគី មេធាវីការពារក្តី ខៀវ សំផន និង មានឱកាសសមស្របសម្រាប់ការឆ្លើយតបទៅនឹង -- កត់សម្គាល់ទៅនឹងការដែលលើកឡើងរបស់ខាងសហព្រះរាជអាជ្ញាចំពោះបញ្ហានេះនៅក្នុងអំឡុងពេលសមស្របណាមួយ ប្រសិនអាចធ្វើបាន។ នៅរសៀលនេះ គឺនឹងធ្វើនៅចុងម៉ោង យើងនឹងសួរបញ្ហាហ្នឹងហើយ បើសិនជាធ្វើមិនបានទេ យើងនឹងមានឱកាសណាមួយ យើងនឹងកំណត់ពេលវេលាដើម្បីលៃទាំងពេលវេលា ទាំងរយៈពេល ដើម្បីធ្វើការឆ្លើយតបចុងក្រោយពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសារក្នុងការឆ្លើយតបទៅនឹងឯកសារគន្លឹះដែលបានដាក់បង្ហាញ ដោយសហមេធាវីការពារក្តីខៀវ សំផន កាលពីម្សិលនោះ។

បាទ សូមអញ្ជើញបាទ!

[១៣:៥៧:២៥]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណ<លោកប្រធាន>។

<សៀវភៅរបស់>ប៉ែន យៀវនិន ក៏ត្រូវបានមេធាវីការពារក្តីដកស្រង់ក្នុងឯកសារ E3/1593 គាត់បាននិយាយអំពីបញ្ហាដែលយើងឮច្រើនដងរួចមកហើយ ហើយបញ្ហានោះ គឺថានៅក្នុងឆ្នាំ៧៥ មជ្ឈិមបានបង្កើតកងទ័ព<ផ្ទាល់ខ្លួន> ដោយដកចេញពី<កងទ័ព>ភូមិភាគ ហើយភូមិភាគមិនមានការជំទាស់ឡើយ ដោយគេអនុញ្ញាតឱ្យ<កងទ័ពទាំងនោះមក>។ ដូច្នេះ ការនេះបង្ហាញថា សិទ្ធិអំណាចរបស់មជ្ឈិម <គ្របដណ្តប់>លើភូមិភាគ ជាពិសេសគឺនៅក្នុងសៀវភៅរបស់ យៀវនិន នៅត្រង់ទំព័រ៩៤ <ERNភាសា>អង់គ្លេសមាន<លេខ> 01150044, <ជាភាសា>បារាំង<លេខ> 00638829 និងភាសាខ្មែរមានលេខ 00637499។ ហើយបន្ថែមពីលើនេះ មានការបង្ហាញអំពីឥទ្ធិពលរបស់មជ្ឈិមទៅលើគោលនយោបាយ គឺគោលនយោបាយ<ដដែល>ដែលយើងបានឃើញ ត្រូវបាន<អនុវត្ត>នៅទូទាំងប្រទេស គឺនៅ<ពេញ>របបកម្ពុជាប្រជាធិបតេយ្យ ក្នុងនោះ គឺការបង្កើតសហករណ៍ ការបង្ខំឱ្យប្រជាជនចូលក្នុងសហករណ៍ ការបង្ខំឱ្យប្រជាជនហូបរួម ការលុបបំបាត់ចោលរូបិយវត្ថុ ការលុបបំបាត់ចោលទីផ្សារ ការផ្សឹកព្រះសង្ឃ នៅក្នុងគ្រប់ភូមិភាគ គ្រប់តំបន់ទាំងអស់ ការហាមឃាត់<>មិនឱ្យប្រណិប័តន៍សាសនា ការរៀបចំដោយបង្ខំនៅទូទាំងប្រទេស ការបែងចែកប្រជាជនទៅជាប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន ឬក៏ជាប្រជាជនពេញសិទ្ធិ ឬក៏ប្រជាជនត្រៀម ការស្រង់ប្រវត្តិរូប និងការស្វ័យទិតៀនជាដើម។

[១៣:៥៩:២៩]

គឺថា មិនមានភាពខុសគ្នាឡើយ ហើយមួយទៀត គឺថាទុកក៏មិនចំណេញ ដកចេញក៏មិនខាត ក៏ដូចជាគោលគំនិតផ្សេងៗ ដែលថាជីកស្មៅត្រូវជីកទាំងឫសជាដើមហ្នឹង គឺយើងឃើញនៅទូទាំងប្រទេសតែម្តង <ជាការអនុវត្តដដែលៗ> គឺប្រជាជនបាត់ខ្លួន<នៅពេលគេ>ហៅទៅរៀនសូត្រជាដើមនោះ។ ហើយយើងឃើញជាទូទៅ <គេ>តែងតែមានការចាក់ភ្លេង ចាក់សំឡេងខ្លាំងៗ <ដើម្បីគ្របលើសំឡេងនៃការកាប់សម្លាប់ នៅតាមកន្លែងផ្សេងៗ>ទូទាំងប្រទេស។ <ពិតណាស់ថា ថ្នាក់ដឹកនាំតាមស្រុក តំបន់ ភូមិភាគ មាន>សិទ្ធិអំណាច<ខ្លាំង តែសិទ្ធិអំណាចនេះ ក៏គេទទួលបានពីថ្នាក់>មជ្ឈិមជាអ្នកប្រគល់សិទ្ធិឲ្យ<ដែរ>។ ដូច្នេះ ហើយគឺថាសិទ្ធិអំណាច<ដ៏ធំ>របស់ពួកគេ<ដែលបុគ្គល ឬក៏រដ្ឋមាននោះ គឺជាអំណាចសម្លាប់មនុស្ស។> យើងដឹង<តាម>ឯកសារ<ដ៏ល្បីមួយ គឺ>E3/12 ដែលជាសេចក្តីសម្រេចរបស់គណៈមជ្ឈិមថ្ងៃទី៣0 មីនា ៧៦ និយាយអំពីសិទ្ធិក្នុងការកម្ទេច សិទ្ធិក្នុងការកម្ទេចក្នុងនិងក្រៅជួរ គឺគេផ្តល់សិទ្ធិទៅដល់ភូមិភាគ ហើយមជ្ឈិមគឺប្រគល់ទៅដល់គណៈ<មន្ទីរ>មជ្ឈិម<ជាផ្នែកឯករាជ្យ> ហើយនិង<>ប្រគល់ទៅដល់គណៈអចិន្ត្រៃយ៍<។ ចំណែក>ខាងទ័ព<វិញ គេប្រគល់ឲ្យសេនាធិការវិញ>។ ទទ្ទីករណ៍មួយទៀតរបស់មេធាវីការពារក្តី គឺថាជនជាប់ចោទ ខៀវ សំផន មិនបានដឹងអំពីអ្វីដែលកើតឡើងនៅក្នុងភូមិភាគ ឬក៏ការឈឺចាប់របស់ប្រជាជន ក៏ដូចជាការអត់ឃ្លានរបស់ប្រជាជននៅតាមទីជនបទនោះឡើយ។ ប៉ុន្តែសម្តេចនរោត្តមសីហនុ បាននិយាយអំពីការធ្វើដំណើររបស់<ទ្រង់>ជាមួយ ខៀវ សំផន ហើយឯកសារមួយបានបង្ហាញ គឺជាឯកសារដែលលើកឡើងនៅក្នុងការសារណាបញ្ចប់ការពិភាក្សាដេញដោល<ក្នុងសំណុំរឿង00២/0១ ឯកសារ> E3/3113R គឺចាប់ផ្តើមម៉ោងនាទី២៩:៣២ ដែលសម្តេច សីហនុ បាន<មានបន្ទូល>ថា “តាំងពីៗខែកញ្ញា ឆ្នាំ៧៥ ដល់ខែមេសា ឆ្នាំ៧៦ ខ្ញុំក្នុងនាមជាប្រមុខរដ្ឋបានធ្វើដំណើរទូទាំងប្រទេសកម្ពុជាជាមួយនឹង ខៀវ សំផន ។ ខ្ញុំឃើញថាតាមឃុំគឺជាជំរំប្រមូលផ្តុំ។ ខ្ញុំឃើញថាតើគេធ្វើការទាំងយប់ទាំងថ្ងៃដោយរបៀបណា នៅពេលដែលព្រះចន្ទរះហ្នឹងប្រជាជនគាត់មិនអាចគេងបានទេ គេមិនឲ្យដេកបាននោះទេ។ ប្រជាជនត្រូវតែធ្វើការ។ ខ្ញុំឃើញថាប្រជាជនហូបអ្វី ហើយឃើញថាមិនមានអង្ករ គឺថាអង្ករគេយកមកលាយជាមួយពោត <>សណ្តែក <ឬដួនកាល>លាយជាមួយស្លឹកឈើ <ឬដើមចេក>គឺការចំណីអាហារវាយ៉ាប់ណាស់។”

[១៤:0២:៤៣]

ហ្វីលីពស្សត ក៏បាននិយាយផងដែរអំពីការសម្ភាសជាមួយសម្តេច<ឪ> គឺនៅទំព័រ<ភាសា> អង់គ្លេស 00396541, បារាំង 00639894 ដែលនិយាយអំពីការធ្វើដំណើរនោះ គឺសម្តេច សីហនុ បានប្រាប់ ហ្វីលីព ស្សត ថា "ប្រជា<រាស្ត្រ>ខ្ញុំត្រូវបានគេធ្វើឲ្យទៅជាគោក្របី"។

ណាយ៉ាន់ ចាន់ដា ក៏បាននិយាយផងដែរអំពីចំណុចនេះ។ គឺនិយាយអំពីសម្តេច សីហនុ ដែលនិយាយអំពីការធ្វើដំណើរ <> គឺឯកសារ E3/2376 គឺ "សត្រូវបងប្អូន"។ អង់គ្លេសមានលេខ 00192 413, បារាំងមានលេខ 00237089, ខ្មែរមានលេខ 00191564 ដែលគាត់និយាយ<>អំពីសម្តេចសីហនុ ដែលព្យាយាមចេញចង់ៗចេញពីឡាន ហើយៗពេលនោះគឺ ខៀវ សំផន បានមកប្រាប់សម្តេចមិនឲ្យចេញពីឡាននោះឡើយ។ ក្រៅពីនេះមេធាវីការពារក្តី ខៀវ សំផន ក៏បាននិយាយអំពីការប្រព្រឹត្តចំពោះប្រជាជនថ្មី គឺមិនមែនជាគោលនយោបាយរបស់មជ្ឈិមនោះទេ ប៉ុន្តែវាជាអ្វីដែលធ្វើឡើងដោយប្រជាជននៅតាមតំបន់ ដែលធ្វើឡើងដោយខ្លួនឯង។ ប៉ុន្តែ<ជាដំបូង>ខ្ញុំ<សូមសួរសិនថា>ហេតុអ្វីបានជាប្រជាជនថ្មីនេះត្រូវបានគេបញ្ជូនទៅតាមទីជនបទ ដើម្បីទៅចែករំលែករបបអាហារជាមួយប្រជាជនដែលមាននៅទីនោះ គឺថាពួកគេមិនមែនទៅដោយខ្លួនឯងនោះទេ <ត្រង់នេះហើយ>គឺវាជាគោលនយោបាយមជ្ឈិម។ ដូចដែល ខៀវ សំផន បានប្រាប់កាសែតញូវយ៉កថែមស៍ គឺ E3/687 គឺអត្ថបទដែលបោះពុម្ពនៅថ្ងៃ០៩ កក្កដា ១៩៨២ អង់គ្លេសមានលេខ 00122280, បារាំងមានលេខ 00622450 និងភាសាខ្មែរមានលេខ 00651187 គឺគាត់បាននិយាយថា ប្រជាជនកម្ពុជារាប់លានត្រូវបានគេបញ្ជូនចេញពីភ្នំពេញទៅទីជនបទដែលវាជាសេចក្តីសម្រេចរួម គឺអត្ថបទបាននិយាយថា ខៀវ សំផន ទទួលស្គាល់អំពីចំណុចទាំងអស់នេះ។ គេសួរថាតើគាត់បានចូលរួមក្នុងការសម្រេចនេះ ឬក៏អត់។ លោក ខៀវ សំផន បានសើចខ្សឹបៗ ហើយនិយាយជាភាសាបារាំងដែលមានន័យថា "បាទ ពិតហើយ"<>។ នៅក្នុងទស្ស-នាវដ្តីទង់បដិវត្តន៍ E3/742 គឺទស្សនាវដ្តីបដិវត្ត<លេខចេញផ្សាយ>ខែមេសា ឆ្នាំ<១៩៧៧> ភាសាអង់គ្លេសមានលេខ 00478505, បារាំងមានលេខ 00499763 និងភាសាខ្មែរមានលេខ 00062997 គឺនៅត្រង់ចំណុចទី៣ គឺបានបញ្ជាក់ថា "<>ត្រូវ<បែងចែកសមាសភាព>ក្នុងសហករណ៍ <ឲ្យច្បាស់លាស់ កុំ>ឲ្យ<ច្របូកច្របល់>ទៀត។" គឺគេរៀបចំអំពីសមាសធាតុបី គឺសមាជិកពេញសិទ្ធិរបស់សហករណ៍ សមាជិកត្រៀម ហើយនិងសមាជិកផ្ញើ។ ខៀវ សំផន ក៏<មានបំណងពន្យល់>នៅក្នុងសៀវភៅរបស់គាត់ដែរ គឺ<ឯកសារ>E3/16 <មានចំណងជើងថា "ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា">ទំព័រភាសាខ្មែរ 00380469, អង់គ្លេស 00498286, បារាំងមានលេខ 00643892 គឺខៀវ សំផន បាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<សរសេរ>ថា៖ "នេះគឺជាគោលការណ៍ប្រុងប្រយ័ត្ន <កុំឱ្យភ្នាក់ងាររបស់ប្រទេសខ្លះ អាចចូលមក> ស៊ីរូង<អំណាច>បដិវត្តន៍កម្ពុជា<បាន>។ ដូច្នេះ <ត្រូវតែក្ដាប់>ប្រវត្តិរូបរបស់បុគ្គលម្នាក់ៗ ហើយ <>ដើម្បីកម្មាភិបាល និងកសិករ <ងាយក្ដាប់ប្រវត្តិរូបម្នាក់ៗ វិធីដែលងាយ>បំផុតនោះ គឺត្រូវបំបែកពួកគេទៅជាប្រជាជនថ្មី និងប្រជាជនចាស់"។ <ហេតុអ្វី? តើ>ហេតុអ្វីបានជាលោក ខៀវ សំផន គិតថាវាចាំបាច់ដែលត្រូវ ប្រសិនបើគាត់គិតថា ចាំបាច់ត្រូវ<>ប្រព្រឹត្តស្មើគ្នា ហេតុអីចាំបាច់ត្រូវបំបែកឱ្យមានភាពខុសគ្នារវាង ប្រជាជនថ្មី និងប្រជាជនចាស់។" ហេតុអ្វីបានជាទស្សនាវដ្ដីទង់បដិវត្តដែលថាៗមេដឹកនាំ<ជាន់ខ្ពស់ បង្គាប់ឱ្យសហករណ៍>បែងចែកទៅជាប្រជាជនពេញសិទ្ធិ ប្រជាជនបម្រុង និងប្រជាជនផ្ញើនោះ<?> គឺគេបង្កើតឱ្យមាន<វណ្ណភាព>ទី២<សម្រាប់>ប្រជាជនថ្មី<ទាំងអស់>។

[១៥:0៧:៥៩]

នៅក្នុងការបង្ហាញពីម្សិលមិញ មេធាវីការពារក្ដីបានយោងទៅលើមាត្រាមួយដែល <រើល> ប៊ើកគ្ល័រ គាត់បាន ក្នុងសៀវភៅរបស់គាត់ ហៅថា "<ភ្នែកម្ចាស់>"។ ទាំងក្រុមមេធាវីការពារក្ដី ខៀវ សំផន និងក្រុម នួន ជា ក៏បានយកមកយោង<ឯកសារមួយនេះដែរ>។ <ខ្ញុំសូមបញ្ជាក់ប្រាប់ថា> សៀវភៅនេះ មិនបានបង្ហាញអំពីគុណវុឌ្ឍិណាមួយរបស់អ្នកនិពន្ធ ហើយមិនបានបង្ហាញអំពីការសិក្សាស្រាវជ្រាវដើមនោះដែរ។<តាមពិតទៅ នេះគ្រាន់តែជានិក្ខេបបទមួយប៉ុណ្ណោះ។> អ៊ីចឹងបើ យើងមើលប្រវត្តិរូបរបស់គាត់នៅចុងបញ្ចប់នៃសៀវភៅនោះ គឺគាត់ថាជាអ្នកថតរូបឱ្យខាងសារព័ត៌មានអស់រយៈពេលជាច្រើនឆ្នាំ។ ក៏ប៉ុន្តែ ប៊ើកគ្ល័រ បាន<លើករឿងរ៉ាវ>ច្រើន<ដែលផ្ទុយពីការលើកឡើងរបស់> ខៀវ សំផន <ហើយបង្ហាញយ៉ាងច្បាស់អំពី>ការទទួលខុសត្រូវរបស់<>ថ្នាក់មជ្ឈិម។<>គឺឯកសារ E3/7333, ERN <ជាភាសាអង់គ្លេស លេខ>00100224។ លោក ប៊ើកគ្ល័រ បានសរសេរថា៖ "មជ្ឈិមយ៉ាងហោចណាស់ក៏ <ក្រុម>ប៉ុល ពត <ទទូច>ថាគោលនយោបាយនេះនិយាយលើកឡើង<>ត្រឹមត្រូវ <ហើយ>ទោះ<បីក្រោយមកទៀតដឹងថា>ខុសក៏ដោយ។ <មជ្ឈិម>មិនចង់ទទួលស្គាល់ថា វាមានបញ្ហាទេ <ហើយមានះ>អនុវត្តគោលនយោបាយនេះ ដែលជាគោលនយោបាយមួយអនុវត្តមិនកើត<ក៏ដោយ>។ <ផ្ទុយទៅវិញគេស្ដីបន្ទោសអ្នកដែលត្រូវអនុវត្តគោលនយោបាយនោះទៅវិញ។>កម្មាភិបាល<ណាប៊ានចេញមុខ>រិះគន់<មាគ៌ា>មជ្ឈិម<ក្នុងគោលបំណងកែលម្អ បែរជាទទួលរងការចោទប្រកាន់ថាជាជន>ក្បត់ទៅវិញ"។ ដូច្នេះមជ្ឈិមបានធានាថា គោលនយោបាយដែលបរាជ័យហ្នឹងត្រូវតែអនុវត្ត<លើផ្នែកណាមួយ ដោយបដិសេធរាល់ការជំទាស់ ឬរាល់ការសួររកមូលហេតុនៃការបរាជ័យ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

នោះ>។<>មេធាវីការពារក្តីបានចំណាយពេលវេលាជាច្រើនម្សិលមិញ និយាយអំពីការនាំស្រូវចេញ ដែលថាបណ្តាប្រទេសទាំងអស់<មានបំណងធ្វើនីហរ័ណកម្មទំនិញ។ វាប្រាកដជាល្អណាស់>ធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើនជឿនលឿន។ នេះជារឿងធម្មតាហើយ <យើង>មិនបាច់សួរនោះទេ។ ប៉ុន្តែ<អ្វីដែលយើងឆ្ងល់នោះគឺ>គឺតើនៅពេលដែលប្រជាជនខ្លួនកំពុងតែអត់ឃ្លាន ហេតុអ្វីក៏នាំស្រូវអង្ករចេញទៅក្រៅប្រទេស<ទៅវិញ>? <តើមានអ្វីទៀត ដែលសំខាន់ជាងការ>ផ្តល់ស្បៀងអាហារឱ្យប្រជាជន<មានជីវិត>រស់នៅទៅ<>? ថ្នាក់ដឹកនាំមជ្ឈិមនោះដឹងអំពីបញ្ហាហ្នឹង<ហើយពួកគេថែមទាំងមានអំនួតនូវទង្វើរបស់ខ្លួនទៀតផង>។ <>នៅក្នុង<ទស្សនាវដ្តី>ទង់បដិវត្ត<>ចុះខែវិច្ឆិកា <ឆ្នាំ១៩៧៦> ERN នេះគឺឯកសារ <E3/139> គឺខ្មែរ ERN 00064966, អង់គ្លេស 00455284, បារាំង 00491920 "យើងត្រូវតែនាំស្រូវចេញបានរាប់រយពាន់តោន នៅក្នុងឆ្នាំ១៩៧៦។ លទ្ធភាពដែលយើង ដែលនាំស្រូវចេញនោះ ក្រោយពី<>សង្គ្រាម<ពិភពលោកទាំងមូលរង>ឥទ្ធិពលយ៉ាងខ្លាំង<>។"

[១៤:១១:១៥]

ខៀវ សំផន ខ្លួនគាត់ផ្ទាល់នេះ នៅក្នុងសុន្ទរកថានៅថ្ងៃទី១៥ <ខែមេសា ឆ្នាំ១៩៧៧> គឺឯក-សារដែលលើកពីម្សិលមិញ E3/201, ERN ជាភាសាអង់គ្លេស 00419513, បារាំង 00612166, ខ្មែរ 00292805។<នេះជាសុន្ទរកថា ដែល> ខៀវ សំផន បាននិយាយ<ទៅកាន់កងទ័ព>ថា៖ "នេះគឺជាមេរៀនមួយដ៏មហាអស្ចារ្យ ជាបទពិសោធន៍ដ៏មហាអស្ចារ្យ<មួយ>។ នៅក្នុងឆ្នាំ៧៦ យើងដោះស្រាយបញ្ហា<របស់យើង> និង<អាច>បំពេញ<តាម>ផែនការផលិតកម្ម។ ជាលទ្ធផល <>យើងបាន<ប្រមូល>ទិន្នផលល្អ<សម្រាប់>ឆ្នាំ៧៧។ ឥឡូវនេះ យើងអាចចិញ្ចឹមប្រជាជន<តាមការបែងចែករបបអាហារបានគ្រប់គ្រាន់ពីរដ្ឋ>។<>យើង<នៅ>សល់ស្រូវអង្ករ<>សម្រាប់នាំចេញផងដែរ។"

ហើយ នួន ជា នោះក៏<អួតអាង>អំពីការនាំអង្ករចេញនោះដែរ នៅថ្ងៃទី<១៦> មករា ១៩៧៧ នៅពេលដែលគាត់ថ្លែងសុន្ទរកថាទៅកាន់កងទ័ព ឯកសារ E3/191, ERN ជាភាសាអង់គ្លេសគឺ S000 04076, ខ្មែរ 00649947, បារាំង <00623113>។ បងធំទី២របស់បក្សនិយាយថា៖ "<>ប្រជាជនយើងមាន<>ហូបគ្រប់គ្រាន់<។ ស្របពេលជាមួយគ្នានេះដែរ>យើង<>មាន<ផលិតផលស្រូវលើសតម្រូវការចំនួន>១៥0ពាន់តោនសម្រាប់សម្រាប់នាំចេញផងដែរ។ <ចំណុច>នេះមានន័យថាយើង<សម្រេចបានតាម>ផែនការឆ្នាំ១៩៧៦ <ទាំងស្រុង>។"

[១៤:១៣:0៩]

<>នៅក្នុងសៀវភៅ ប៉ែន ឃៀរនិន<>ឯកសារ<>E3/1593, <ERN ជាភាសា>បារាំង <មានលេខ> 00639160, អង់គ្លេស 01150196, ខ្មែរ 00637932<> គាត់បាននិយាយថា៖ "មានជន<ភៀសខ្លួន> និងអ្នករស់រានមានជីវិតបាននិយាយថា មានអង្ករជាច្រើនត្រូវបានគេដឹកទៅប្រទេសចិន ទោះបីជាមាន<>ភាពអត់ឃ្លាន<កំពុងរាតត្បាត>យ៉ាងខ្លាំងនៅក្នុងប្រទេសក៏ដោយ។" <គេ>ថា នៅក្នុងឆ្នាំ<១៩៧៨ កម្មាភិបាល>កម្ពុជាប្រជាធិបតេយ្យ<បាន>នាំ<ចេញ>អង្ករ<>១០០ពាន់តោន <នៅឆ្នាំមុន >ទៅបណ្តាប្រទេសមួយចំនួន ដូចជា យូហ្គោស្លាវី ម៉ាដាហ្គាស្កា និងហុងកុងជាដើម។"

ឯកសារមួយផ្សេងទៀត ដែលជាឯកសារបានមកពីលោក លឹមគិន សម្ភាសជាមួយនឹង ទាត់ <ធឿន> គឺឯកសារ E3/10665។ <>ទាត់ ធឿន <>ជាកូនចិញ្ចឹមរបស់ រស់ ញឹម <ពុំមាន ERN ជាភាសាបារាំងទេ> ERN ជាភាសាខ្មែរ 01168475, អង់គ្លេស 01156820 គាត់បាននិយាយថា <រស់ ញឹម ថ្លែងថា៖> "ចំនួនស្រូវ<នេះត្រូវ>យកទៅឲ្យអង្គការ<តាម>ផែនការកំណត់ ទោះបីជាប្រជាជន<>មានតែបបរហូបក៏ដោយ<។ ស្រូវក៏មិនមានផង មានអីយកទៅកិន>។" ហើយ ទាត់ ធឿន បាន<បន្ត>ថា៖ "នេះហើយគឺជាផែនការរបស់មជ្ឈិម បើសិនណាមិនមានអង្ករទៅឲ្យមជ្ឈិមឲ្យបានគ្រប់ផែនការទេ គេចោទថាយើងក្បត់ហើយ។"

[១៥:១៥:១៣]

ហើយលោក ប៉ែន ឃៀរនិន នៅក្នុងសៀវភៅរបស់គាត់ដដែល<ដែលខ្ញុំបានដកស្រង់មុននេះ> ត្រង់ទំព័រ<ERNជាភាសាបារាំង លេខ 01105217>, <ជាភាសា>ខ្មែរ<លេខ 00637991>។ <គាត់បានដកស្រង់ពីប្រជាជនចាស់ម្នាក់ឈ្មោះ> សារី <>បាននិយាយថា៖ "កម្មាភិបាលភូមិភាគនិរតីបានចោទទៅខាងភូមិភាគពាយ័ព្យ <ពីការឲ្យប្រជាជនហូបបបរ នៅពេលដែលស្រូវ អង្ករមានបរិបូរ ប៉ុន្តែក្រោយមកពេលគេមកកាន់កាប់ គេឲ្យយើងហូបតិចជាងមុនទៅទៀត>"។

<ផ្ទុយពីជំហររបស់>ក្រុមមេធាវីការពារក្តី ខៀវ សំផន បានជំទាស់ពីម្សិលមិញថា មជ្ឈិមហ្នឹងគឺថាមិនបានទទួលអ្វីដែលកើតឡើងនៅភូមិភាគនោះទេ ហើយភូមិភាគហ្នឹងតែងតែ<មិន>លាក់បំបាំងនូវអ្វីដែលកើតឡើងនៅក្នុងភូមិភាគរបស់ខ្លួន<។ យើងមានឯកសារនៅក្នុងសំណុំរឿង> គឺឯកសារ E3/179 ដែលជាសារទូរលេខផ្ញើទៅមជ្ឈិមពីមន្ទីរ៥៦០ នៅថ្ងៃទី២៩ <ខែឧសភា ឆ្នាំ១៩៧៧> គឺមន្ទីរភូមិភាគពាយ័ព្យ។ នៅ<ខាងក្រោម>ផ្នែក<ទី២៖>ស្ថានភាពប្រជាជន <ចំពោះភាសាទាំងអស់ហ្នឹងមានខ្លឹមសារដូចតទៅ៖>។ "ជីវភាពរស់នៅរបស់ប្រជាជនគឺមានការខ្វះខាត<នៅក្នុងតំបន់ជាច្រើន>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

។ នៅក្នុងតំបន់១, ២, ៤, ៦ និង ៧ ប្រជាជន<>អត់មានអីហូប<ទេ។ អ្នកនៅសមរភូមិក្រោយហូបបបរភាវ១ រីឯអ្នកនៅសមរភូមិមុខវិញមានរបបហូបរហូតដល់ពីរកំប៉ុងក្នុងមួយថ្ងៃ។>"

[១៥:១៦:៤៩]

សារទូរលេខមួយទៀតដែលផ្ញើដោយ រស់ ញឹម នៅថ្ងៃទី១១ <ខែឧសភា ឆ្នាំ១៩៧៨> គឺ<> មួយខែមុនពេលគាត់ត្រូវបានចាប់ខ្លួនបញ្ជូនទៅស-២១។ <>គឺជាឯកសារ E3/950 <នៅចំណុចទី២> គាត់និយាយថា៖ "ការខ្វះខាតនៅក្នុងភូមិភាគនេះ គឺមាននៅក្នុងតំបន់១, ៤ និង ៥ <ទាំងអស់តំបន់៥> ខ្វះ<ជាងគេ រួចមកតំបន់>១ និងតំបន់៤។ <តំបន់៥ថា ខ្វះទាំងបួន>ស្រុក។" <ទូរលេខនោះបន្តទៀតចុះបន្តិចថា៖ យើងឃើញថាមានអង្ករដែលអង្គការបញ្ជូនមកនោះ នឹងអស់ក្នុងថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨។"> អ៊ីចឹងនៅក្នុងខែឧសភា ឆ្នាំ១៩៧៨ រស់ ញឹម បានជូនព័ត៌មានសារទូរលេខមកមជ្ឈិមឲ្យមជ្ឈិមបានដឹងអំពីបញ្ហានេះ ក៏ប៉ុន្តែយើងដឹងថាទោះជាយ៉ាងនេះក្តី មជ្ឈិមនៅតែបន្តនាំស្រូវចេញទៅក្រៅប្រទេសដដែល"។

<មានរបាយការណ៍ពីរទៀត ទទួលបានពីកន្លែងផ្សេងគ្នាក្នុងប្រទេស គឺ>ឯកសារ E3/1060 គឺជារបាយការណ៍មកពីកងពល៨០១ ចុះថ្ងៃទី២៩ <ខែមីនា ឆ្នាំ១៩៧៧> ERN ជាភាសាអង់គ្លេស 00574313, បារាំង <00529407>, ខ្មែរ <00231374>។ របាយការណ៍នេះនិយាយថា ភូមិ<ចំនួន>បី<នៅសហករណ៍៣៦> គឺប្រជាជនមានភាពអត់ឃ្លានតាំងពីខែកុម្ភៈ ឆ្នាំ១៩៧៧" <ដូចគ្នានោះដែរក៏បានលើកឡើងពី>សហករណ៍លេខ<>៣៥<ផងដែរ>។

ឯកសារ E3/918 ជាសារទូរលេខមកពី សែ ផ្ញើជូនគណៈ៨៧០ ចុះថ្ងៃទី១០ <ខែមករា ឆ្នាំ១៩៧៨> កថាខណ្ឌទី២<មើលពីក្រោម គាត់បានរាយការណ៍ថា៖> "នៅតំបន់<>ព្រះវិហារ<>កន្លែងភាគច្រើន<>កំពុងតែប្រឈមនឹងភាពអត់ឃ្លាន។" ដូច្នេះយើងឃើញហើយ មិនមែនថាមជ្ឈិមមិនបានទទួលបានព័ត៌មាននោះទេ មជ្ឈិមរួមមាន ខៀវ សំផន <និង>នួន ជា<។ ពួកគាត់គួរតែបានឃើញច្បាស់ជាង>សម្តេច នរោត្តម សីហនុ បានទត<>ឃើញអំពីស្ថានភាព<ទុរភិក្សរបស់ប្រជានុរាស្ត្ររបស់ព្រះអង្គ ទៅទៀត។> ពួកគេ<>ជាអ្នកគ្រប់គ្រងអំពីការចាត់ចែងស្រូវអង្ករ។

[១៥:១៩:២៩]

ឯកសារ<មួយទៀតដែលមេធាវីប្រើប្រាស់កាលពីម្សិលមិញ> E3/230 <ត្រង់លេខរៀងទី៧> យើងឃើញហើយ នេះគឺគណៈអចិន្ត្រៃយ៍មានកិច្ចប្រជុំហ្នឹង គឺសមមិត្ត ហែម ក៏មានវត្តមានចូលរួមប្រជុំ

<ហើយគាត់ក៏បានចូលរួមក្នុងការសម្រេចចិត្ត>បែងចែកស្រូវអង្ករមានទៅកន្លែង<ជាក់លាក់មួយចំនួន។ តាមុត--> មាស មុត <>និងទៅតំបន់២៥ <បញ្ជាក់ថា>មជ្ឈិម<មានអំណាច>ក្នុងការចែកអង្ករ។

ឯកសារ<មួយទៀតដែលខ្ញុំលើកឡើងដោយសង្ខេប ហើយ>មេធាវីការពារក្ដីយកមកប្រើពីម្សិលមិញ<ដែរ> គឺ E3/222 កិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍មួយទៀតគឺនៅថ្ងៃទី១៥ <ខែឧសភា ឆ្នាំ១៩៧៦។> របៀបវារៈ<តែមួយគត់ដែលគេលើកឡើង>ហ្នឹងគឺនិយាយអំពីបញ្ហាការពារជាតិ។ ហើយខ្ញុំយល់ឃើញថា វាគួរឲ្យចាប់អារម្មណ៍ណាស់ ឃើញ ហែម –សមមិត្តហែម គឺ ខៀវ សំផន– គឺថាគាត់បានចូលរួមប្រជុំហើយ <>គាត់ក៏បាន<រួមចំណែកក្នុង>ផ្នែក<>ការពារជាតិថែមទៀតផង។

ចុងបញ្ចប់នៃការបង្ហាញឯកសារកាលពីម្សិលមិញ មេធាវីការពារក្ដីបានជំទាស់ថា ខៀវ សំផន អត់បានដឹងអ្វីទាល់តែសោះអំពីស-២១ នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ អៀង ធីរិទ្ធ នេះក៏បានបញ្ជាក់ផងដែរថា គាត់មិនបានដឹងអំពី<ការចាប់មនុស្សបញ្ជូនមកកាន់>មន្ទីរសន្តិសុខស-២១ នេះទេ។ <គាត់ក៏បញ្ជាក់ថានោះជាការប្រឌិតរបស់វៀតណាម។> អៀង ធីរិទ្ធ បាននិយាយថា គាត់និង ខៀវ សំផន <បានមើលឯកសារអំពី ស-២១ ខណៈពេលដែលគេទាំងពីរនាក់ទៅទីក្រុងឡាហាវ៉ាន់ក្នុងឆ្នាំ១៩៨០ ក្រោយពីរបបខ្មែរក្រហមដួលរលំ>ឯណោះ។ ប៉ុន្តែ ខៀវ សំផន នេះក្នុងសៀវភៅរបស់គាត់គឺ E3/18 “<ពិចារណាអំពី>ប្រវត្តិសាស្ត្រកម្ពុជា<>” <ដោយប្រាប់ថាគាត់បានដឹងនៅពេលវេលាផ្សេងពីនេះទៅវិញ>។ គាត់បានអះអាងថា<គាត់មិនបានដឹងពីវត្តមាននៃមន្ទីរនេះទេ ទាល់តែគាត់បានឃើញភាពយន្តឯកសាររបស់> រិទ្ធី <ប៉ាន់ មានចំណងជើងថា>“ស-២១<> – ម៉ាស៊ីនសម្លាប់មនុស្ស” <ទើបគាត់ដឹងពីទីកន្លែងនោះ>។ <ភាពយន្តនោះមិនមែនចាក់បញ្ចាំងនៅទសវត្សរ៍ឆ្នាំ៨0 ឯណា>គឺ<>ក្រោយ<យូរ>មែនទែន<>ក្រោយពីដំណើរគាត់ទៅទីក្រុង<ឡាហាវ៉ាន់>។ <យើងឃើញថា មេធាវីការពារក្ដីបានបង្ហាញតាមរយៈ> អៀង ធីរិទ្ធ <គឺ> ខៀវ សំផន នេះកុហកហើយ<>។ <គាត់ថាទាល់តែបានមើលរឿងរបស់ រិទ្ធី ប៉ាន់ ទើបគាត់ដឹងពីស-២១ បើតាម> អៀង ធីរិទ្ធ បាននិយាយថា បាន<មើលឯកសារ> ស-២១ ជាមួយគ្នានឹង ខៀវ សំផន នៅទីក្រុង<ឡាហាវ៉ាន់>។

[១៤:២២:0៣]

ក៏ប៉ុន្តែអ្នកដែលមានតួនាទីមួយដូច ខៀវ សំផន <>ជា<មនុស្សនៅក្នុង>រង្វង់មួយជាមួយនឹង ប៉ុល ពត គាត់ជាមនុស្សដែល ប៉ុល ពត ទុកចិត្ត គាត់ជាគណៈប្រធានរដ្ឋ <គាត់ជាសមាជិកខុទ្ទកាល័យពាណិជ្ជកម្ម ហើយជារឿយៗ>គាត់<>មានវត្តមានចូលរួមប្រជុំ<>ជាមួយនឹងគណៈអចិន្ត្រៃយ៍<អ៊ីចឹង

គាត់ជាមនុស្ស>តែម្នាក់គត់<នៅក្នុងប្រទេសកម្ពុជាដែល>មិនដឹងអំពីការចាប់ខ្លួនទាល់តែសោះ <ហើយ អ៊ីចឹង វាមិនគួរជឿទេ>។ ឯកសារមួយ<ក្នុងចំណោមឯកសារ>ដែលមេធាវីការពារក្ដីបានលើកឡើងនោះគឺ កិច្ចសម្ភាសន៍ជាមួយនឹង<>ខូ វណ្ណី ដែលជាអ្នកធ្វើការនៅក្រសួងសង្គមកិច្ចជាមួយ អៀង ធីរិទ្ធ។ គាត់នេះត្រូវបាន អៀង ធីរិទ្ធការពារ។ គាត់បាននិយាយថាតើគាត់បានដឹងពីការចាប់ខ្លួនដោយរបៀបណានោះ។ ERN ជាភាសាអង់គ្លេស 00442654, បារាំង 00614084, ខ្មែរ 00602364។ គាត់បានពន្យល់<យ៉ាង>លម្អិតអំពីការចាប់ខ្លួន កុយ ធួន ហើយនិង<ឈ្មោះ ជួន> ដែលជាអនុប្រធានមន្ទីរពាណិជ្ជកម្ម ហើយនិងអ្វីដែលប្រជាជននិយាយថា <មូលហេតុដែលគេចាប់>អ្នកទាំងពីរ<នាក់នោះ>។

<គាត់រៀបរាប់ប្រហែលជាពីរបីទំព័រ>នៅត្រង់ទំព័រ<>ដែល<>គាត់ក៏បាននិយាយអំពីការចាប់ខ្លួន ហ៊ូ នឹម <>ថា៖ “ហ៊ូ នឹម <និងបញ្ញាជនជាច្រើននាក់ទៀតទាំងនៅក្នុង និងមកពីក្រៅប្រទេសត្រូវគេចាប់ខ្លួន”>។ <គាត់លើកឡើងពីអ្នកទាំងនោះ។> តើធ្វើម៉េចបានជា<ខូ វណ្ណី>ដឹងអំពីការចាប់ខ្លួន ហ៊ូ នឹម <ដែលជនម្នាក់នេះស្ថិតនៅក្នុងចំណោមជនបាត់ខ្លួនទាំងបី ដែលជាសមាជិករដ្ឋសភា ហើយក៏ជាអ្នកស្និទ្ធនឹងលោក ខៀវ សំផន ផងដែរ។ ចុះហេតុអ្វីបានជា ខៀវ សំផន>ដែលជាមិត្តភក្ដិជិតដិតជាមួយ<គាត់>អត់ដឹងការចាប់ខ្លួន<>នេះទាល់តែសោះ<?>។ គាត់ក៏បាននិយាយអំពី<ការចាប់ខ្លួនឈ្មោះ> ប៉ង់ <បន្ទាប់ពីគេចាប់> វន វ៉េត <រួចមក>។ ហើយអ្នកទាំងអស់នេះ ខៀវ សំផន <ស្គាល់ទៀតផង។> ហេតុអ្វីបាន ខូ វណ្ណី ហ្នឹង<>ដឹង ហើយ ខៀវ សំផន អត់ដឹងសោះ<អ៊ីចឹង?>។

[១៤:២៤:១២]

អ៊ីចឹង ខៀវ សំផន គឺគាត់មិនមានភាពស្មោះត្រង់ជាមួយ<អង្គជំនុំជម្រះ និងជាមួយ>ប្រជាជនកម្ពុជាទេ <ដែលថា>គាត់មិនដឹង<>អំពីការបោសសម្អាត <ឬ>ការចាប់ <ឬការបាត់>ខ្លួនណាមួយនោះ<>។ សូម្បីការចាប់ខ្លួននៅតាម<តំបន់>ក៏ត្រូវរាយការណ៍ជូនមជ្ឈិមដែរ<។> ឯកសារ E3/232 ដែលជាកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ចុះថ្ងៃទី០៨ <ខែមីនា ឆ្នាំ១៩៧៦>, ERN អង់គ្លេស 0018 2628, ខ្មែរ 00017116, បារាំង 00323932។ កំណត់ហេតុនេះនិយាយថា មេដឹកនាំមកភូមិភាគឧត្តរ សមមិត្ត ស្រេង, តំបន់១០៣ សមមិត្ត ហង់, តំបន់១០៦ សមមិត្ត សុត បាន<មក>រាយការណ៍ជូនថ្នាក់ដឹកនាំបក្សនៅទីក្រុងភ្នំពេញ រួម ក្នុងនោះរួមមានការរាយការណ៍ជូន នួន ជា និង ខៀវ សំផន ហើយនិងបានរាយការណ៍អំពីការចាប់ខ្លួន ហើយនិងចំនួនប្រជាជនដែលធ្លាក់ខ្លួនឈឺយ៉ាងច្រើននៅតាមការដ្ឋាននានា។ កិច្ចសម្ភាសន៍មួយទៀតជាមួយនឹង ខៀវ សំផន គឺឯកសារE3/608, ERN ជាភាសាខ្មែរ

<00635929>, បារាំង 00632566, អង់គ្លេស 00419841។ អ្នកសម្ភាសបាន<លើក>ថាមាន<> ប្រជាជន៨00ពាន់<>នាក់<ស្លាប់>ក្រោយពីសង្គ្រាម<ស៊ីវិល។ ការចោទប្រកាន់នេះមានដូចជាការធ្វើទុក្ខបុកម្នេញពីខ្មែរក្រហមមកលើបុគ្គលជាច្រើនរូប ដោយសារហេតុផលនយោបាយ> ហើយ ខៀវ សំផន បានឆ្លើយថា “<ជន>ក្បត់ទាំង<នោះ>ដែល<ស្ថិត>នៅក្នុង<>កម្ពុជា<ប្រជាធិបតេយ្យ>ត្រូវ<កាត់ទោសប្រហារជីវិត>ហើយ។”<នេះគឺជាចម្លើយរបស់គាត់ក្នុងកិច្ចសម្ភាសន៍តបទៅនឹងអ្នកសារ-ព័ត៌មានអ៊ីតាលីម្នាក់។>

[១៤:២៦:១៩]

ឯកសារE3/628 គឺជាកិច្ចសម្ភាសន៍មួយទៀត តាំងពី<យូរមកហើយ ខ្ញុំគ្មានកាលបរិច្ឆេទជាក់លាក់ក្នុងដៃទេ តែវាកើតឡើង>ក្នុងឆ្នាំ១៩៨0មកម្ល៉េះ។ ERN ជាភាសាអង់គ្លេស 00524517, ខ្មែរ 00709544, បារាំង 00740914។ គេបានសួរ ខៀវ សំផន ថា “តើ<>ប្រជាជនប៉ុន្មាន<ត្រូវបានសម្លាប់ក្នុងការធ្វើបដិវត្តន៍របស់លោក>?” គាត់និយាយថា “អ្វីដែលខ្ញុំអាចនិយាយគឺ<>មិនលើសពី ១0.000នាក់ទេ។” អ៊ីចឹង អ្វីដែលគាត់អះអាងអំពីការមិនដឹង ការចាប់ខ្លួន <និងការកាប់សម្លាប់>នៅពេល<នោះទេ>។ <ផ្ទុយទៅវិញ មានគ្រាមួយគាត់ប្រាប់អ្នកសារព័ត៌មានខណ:ដែលគាត់ធ្វើជាតំណាងខ្មែរក្រហមដែលនៅសេសសល់នោះ>ថា ប្រហែលជា១0.000នាក់ទេ<ត្រូវ>បានសម្លាប់នៅក្នុងរបបនោះ។ នៅក្នុងកិច្ចសម្ភាសន៍គាត់ របស់គាត់ជាមួយ ស្ទីវ ហេដឌ័រ នៅក្នុងឆ្នាំ១៩៨0 គឺឯកសារE3/203, ERN ជាភាសាអង់គ្លេស <00424013>, បារាំង 00434232, ខ្មែរ 00385409*<(ស៊ីក)>*។ ខៀវ សំផន បានបញ្ជាក់ថា “វៀតមិញនេះ បានបង្កើតភ្នាក់ងារដើម្បីបម្រើគោលបំណង<យុទ្ធសាស្ត្រ> ឥណ្ឌូចិនរបស់ខ្លួន។ <ចាប់តាំងពីពេលនោះមក ពីមួយឆ្នាំទៅមួយឆ្នាំ> ភ្នាក់ងារទាំងអស់<នោះកាន់តែច្រើនឡើង ហើយ>ទទួលតួនាទីសំខាន់<>ៗ អ្នកខ្លះទទួលបន្ទុក ទទួលកាន់កាប់មុខងារជាមេភូមិភាគ ហើយគេចាប់ផ្តើម<បង្កូចមាគ៌ារបស់យើង>។<វាមានគោលបំណងវាយយើងពីខាងក្នុងមកវិញ។ ប៉ុន្តែយើងវាយវាជាប់ជាប្រចាំ ប្រឆាំង និងរារាំងមហិច្ឆតាពួកវា។> មកដល់ឆ្នាំ១៩៧៧, <១៩៧៨ ទើប> យើងបានចាត់ចែងដោះស្រាយ<ជាមួយពួកវា>ចប់សព្វគ្រប់<ជាស្ថាពរ> ហើយ<នាំយកសណ្តាប់ធ្នាប់ឱ្យ>ប្រទេសជាតិ<ឡើង>វិញ។” <ស្តាប់ទៅឮ>ដូច នួន ជា និង ប៉ុល ពត និយាយពន្យល់អំពីការសម្លាប់កម្មាភិបាលជាន់ខ្ពស់មួយចំនួនផងដែរ។ នេះ ខៀវ សំផន <>គឺថាបង្ហាញហើយ ថាគាត់បានដឹងច្បាស់ណាស់ អំពីមាគ៌ារបស់ប៉ុល ពត នេះ ហើយនិងមូលហេតុនៃការសម្លាប់កម្មាភិបាលជាន់ខ្ពស់នៅ

ទូទាំងប្រទេសនោះ។

[១៤:២៨:៤២]

នៅទំព័របន្ទាប់នៃកិច្ចសម្ភាសន៍នេះផងដែរ <>ហេដឌ័រ សួរ<គាត់ថា "តើ>នៅក្នុងឆ្នាំ<១៩៧៥ ពួកនោះប៉ុន្មានភាគរយ>មានឋានៈខ្ពស់ៗនៅក្នុងជួរបក្ស <>នៅថ្នាក់<គណៈ>មជ្ឈិម <ឬនៅគណៈ> អចិន្ត្រៃយ៍ហ្នឹង?" <ហេដឌ័រ សួរសំដៅទៅលើភាគរយនៃភ្នាក់ងារវៀតណាមដែល ខៀវ សំផន និយាយសំដៅមុននេះ។> គាត់ឆ្លើយថា "<មាន>ច្រើនណាស់។ <ជិតពាក់កណ្តាល>នៅក្នុងគណៈមជ្ឈិមហ្នឹង <ហើយ>ជាងពាក់កណ្តាល<>នៅគណៈអចិន្ត្រៃយ៍<>។" <ដូច្នេះ ខៀវ សំផន ដឹងច្បាស់ណាស់ពីការ>ស៊ើបអង្កេតដោយ<សន្តិសុខ ដោយសន្តិបាល>ស-២១ ដើម្បីធ្វើយុត្តិកម្មទៅលើការកាប់សម្លាប់ទាំងអស់នេះ ដែលថាគេសម្លាប់នោះ គឺសម្លាប់តែភ្នាក់ងារ សេ.អ៊ី.អា<> និងភ្នាក់ងារយួនទេ។

ឯកសារE3/3169 អត្ថបទរបស់ ស្ទីវ ហេដឌ័រ ផងដែរ និយាយអំពីតួនាទីរបស់ ខៀវ សំផន។ <>ខ្ញុំ<ជឿថា ខាងមេធាវីការពារក្តីក៏បានដកស្រង់អត្ថបទនេះផងដែរ កាលពី>ម្សិលមិញ< ឬក៏អត់ទេ តែ>នៅត្រង់លេខយោងជើងទំព័រ៥០នៃអត្ថបទនេះ<លោក> ហេដឌ័រ គាត់បាន<សរសេរ>ថា "អ្នកដែលមានមុខ តួនាទីសំខាន់ៗ១៦នាក់ <នៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា(ហ្រ្គុង) និងអ្នកនៅក្នុង>រណសិរ្សរួមរួបជាតិកម្ពុជា<(ហ្វ៊ុង) ដែលលោក> ខៀវ សំផន <មានទំនួលខុសត្រូវដែរ មាន> ប្រាំបួន<នាក់ត្រូវគេយកទៅសម្លាប់។" ប្រាំបួននាក់>ក្នុងចំណោម១៦ <ដែល ខៀវ សំផន មានទំនួលខុសត្រូវនៅក្នុង ហ្រ្គុង និងហ្វ៊ុង <>ត្រូវបានគេសម្លាប់ចោលអស់។ <តែគាត់បញ្ជាក់ថាគាត់មិនបានដឹងពីការកាប់សម្លាប់ និងការបាត់ខ្លួននោះទៅវិញ>។

[១៤:៣០:២៨]

នៅក្នុងសៀវភៅ<ហ្វីលីព ស្បត >ដែលមេធាវីបានលើកដែរ គឺ E3/9, អង់គ្លេសមានលេខ 00396574, ខ្មែរមានលេខ 01152652 <*(ស៊ីក)*>, បារាំងមានលេខ 00639935។ គឺគាត់បានសរសេរថា <"ចម្លើយ>សារភាពនៃអំពើក្បត់ គឺត្រូវការចាំបាច់សម្រាប់មនុស្សដូចជា អៀង សារី និង ខៀវ សំផន ឲ្យគាត់អាននៅក្នុងការប្រជុំ<សម្ងាត់ក្នុងជួរបក្ស ដោយថា>អង្គការមានភ្នែកច្រើនដូចជាភ្នែកម្នាស់ គឺមិនមានអ្វីអាចគេចផុតពីការ<តាមដាន>របស់អង្គការបានឡើយ។" ដូច្នេះ ហ្វីលីព ស្បត បានបញ្ជាក់ថា ខៀវ សំផន បានអានទូវចម្លើយសារភាពទាំងអស់។ ការសម្លាប់នេះ <ទាំងនៅមជ្ឈិម និង> នៅតាមភូមិភាគ គឺ<> ខៀវ សំផន <ជាតួអង្គដ៏សំខាន់> ព្រោះគាត់ជាអ្នកលើកកម្ពស់ <និងការពារ>

គោលនយោបាយរបស់បក្ស<។> នៅក្នុងសេចក្តីថ្លែងការណ៍<ខួបប្រចាំឆ្នាំ>របស់គាត់ថ្ងៃ១៥ <ខែមេសា ឆ្នាំ១៩៧៧> គឺ E3/201, អង់គ្លេសមានលេខ 00419517, ខ្មែរមានលេខ 00292813 និងបារាំងមានលេខ 00612172។ខៀវ សំផន បាន<ថ្លែង>ថា៖"យើងត្រូវតែលើកកម្ពស់ស្មារតី ប្រុងប្រយ័ត្នបដិវត្តន៍គ្រប់ពេលវេលាប្រឆាំងជាមួយខ្មាំងពីគ្រប់ទីកន្លែង ទាំងក្នុងប្រទេស និង ក្រៅប្រទេស។"

ហើយនៅក្នុងសុន្ទរកថាឆ្នាំបន្ទាប់ គឺឯកសារ E3/562,អង់គ្លេសមានលេខ S00010563, ខ្មែរមានលេខ 00249989 និងបារាំងមានលេខ 00280379។ ខៀវ សំផន បានប្រាប់កម្មាភិបាលជាច្រើន<ដែលមានសមត្ថកិច្ចនៅតាមភូមិភាគ តាមស្រុក និងឃុំ ថា៖ "យើងគ្រប់គ្នាប្តេជ្ញា>ដូចតទៅនេះ។ លេខ៥ កម្ទេចទាំងស្រុងនៅភ្នាក់ងាររបស់ពួក<ឈ្លានពាន ពួក>វាតទីនិយម <វៀតណាមសាហាវព្រៃផ្សៃ ដែលមាននៅក្នុងអង្គភាព ព្រមទាំង>ទឹកដី<ប្រទេស>កម្ពុជា<យើង>។ ទី៦ កម្ទេច<ឲ្យអស់រាល់>ភ្នាក់ងារ សេ.អ៊ី.អា ។ ទី៩ កម្ទេច<>ខ្មាំង<គ្រប់រូបភាពទាំងអស់>។

លោក លោកស្រីចៅក្រម <យើងជឿថា មាន>ឯកសារ <និងភស្តុតាងទាំងឡាយច្រើនណាស់>នៅក្នុងសំណុំរឿង <ដែលមិនត្រឹមតែ>បង្ហាញថា ខៀវ សំផន <បាន>ដឹង<អំពីការកាប់សម្លាប់>ប៉ុណ្ណោះទេ<>ប៉ុន្តែគាត់<ក៏>បានចូលរួមយ៉ាងសកម្ម <ជួយ>សម្របសម្រួល <ហើយនិងញុះញង់>យ៉ាងសកម្មដល់<យុទ្ធនាការកាប់សម្លាប់នេះ>នេះ។

សូមថ្លែងអំណរគុណចំពោះអង្គជំនុំជម្រះ ដែលបានយកចិត្តទុកដាក់ស្តាប់។ សូមអរគុណ។

[១៤:៣៣:៤១]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំមានការកត់សម្គាល់មួយពាក់ព័ន្ធនឹងអ្វីដែលបានកើតឡើងនៅថ្ងៃនេះ នៅចំពោះមុខអង្គជំនុំជម្រះ។ ខ្ញុំគិតថា យើងទាំងអស់គ្នាមិនមែនឆោតល្ងង់ទេ។ យើងដឹងច្បាស់ សហព្រះរាជអាជ្ញា គឺគាត់ព្យាយាមប៉ះប៉ូវនូវការខកខានរបស់គាត់ក្នុងការមិនបានបង្ហាញឯកសារពាក់ព័ន្ធនឹងតួនាទីរបស់ ខៀវ សំផន ហើយភស្តុតាងជាក់ស្តែងបំផុតនោះ គឺថាជាច្រើនលើកច្រើនសា សហព្រះរាជអាជ្ញាបាននិយាយ បានលើកឡើងនៅឯកសារមួយចំនួន។ ខ្ញុំ<យ៉ាងហោចណាស់មាន>ឯកសារបី ដែល<លើកឡើងវា>យើងបានបង្ហាញកាលពីម្សិលមិញ <តាមពិតមិនត្រឹមត្រូវទេ> យើងអត់បានបង្ហាញឯកសារហ្នឹងទេ<>។ ដូច្នេះ ថ្ងៃនេះយើងមិនអាចឆ្លើយតបបានទៅនឹងការកត់សម្គាល់របស់សហព្រះរាជអាជ្ញា ដូចដែលអង្គជំនុំជម្រះឲ្យយើងធ្វើនៅថ្ងៃហ្នឹងទេ។ ខ្ញុំអាចនិយាយដោយខ្លីថា ហេតុអ្វីបានយើង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិនអាចធ្វើបាន។ គឺយើងត្រូវតែមានឯកសារជាមុន បញ្ជីឯកសារជាមុន មានលេខ ERN មានលេខឯកសារជាមុន មុនពេលដែលសហព្រះរាជអាជ្ញាគាត់ធ្វើការបង្ហាញ។ អ៊ីចឹងយើង ទាល់តែយើងដឹងមុនបានយើងអាចពិនិត្យមើលបាន យើងមើលថាតើបរិបទហ្នឹងយ៉ាងម៉េច គេសរសេរពេលហ្នឹងយ៉ាងម៉េច ហើយបើឲ្យពេលតែប៉ុន្មាននាទីវាឲ្យយើងឆ្លើយតបហ្នឹង ឃើញថាយើងមិនអាចធ្វើបានទេ។ អ៊ីចឹងនេះជាការឆ្លើយតបទៅនឹងការស្នើសុំរបស់ ចៅក្រម ឡាវែន៍ ឲ្យយើងឆ្លើយនៅរសៀលនេះ។ អ៊ីចឹងយើងធ្វើមិនបានទេ ពាក់ព័ន្ធទៅនឹងឯកសារដែលសហព្រះរាជអាជ្ញាបានលើកឡើងមុននេះអម្បាញ់មិញនេះ ហើយសហព្រះរាជអាជ្ញាអម្បាញ់មិញនេះមិនមែនតែជាការឆ្លើយតបទៅនឹងឯកសាររបស់យើងទេ គឺគាត់ព្យាយាមប៉ះប៉ូវនៅអ្វីដែលគាត់មិនបានបង្ហាញពាក់ព័ន្ធនឹងតួនាទីរបស់លោក ខៀវ សំផន នោះ។ ហើយបើអង្គជំនុំជម្រះនៅតែឲ្យយើងឆ្លើយតបទៅនឹងការបង្ហាញរបស់សហព្រះរាជអាជ្ញានៅថ្ងៃនេះ គឺខ្ញុំសូមជម្រាបដោយត្រង់ថាយើងខ្ញុំមិនអាចធ្វើបានទេលោកប្រធាន។

[១៤:៣៦:០០]

**លោក នីកូឡាស គូមជែន៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតឆ្លើយតប។ ខ្ញុំប្រសិនបើជាការល្អប្រសិនបើមេធាវីការពារក្តីអាចបង្ហាញថាតើព្រះរាជអាជ្ញាលើកយកឯកសារណាដែលថាមេធាវីការពារក្តីមិនបានបង្ហាញនោះ។ ខ្ញុំសូមលើកករណីមួយទៀត គឺនៅម៉ោង<១១:២០:១៨វិនាទី> <ថ្ងៃ៣០> ខែមេសា <ឆ្នាំ២០១៥> គឺថាលោក លីសាក់<កត់សម្គាល់ថា មេធាវីការពារក្តីបានប្រើប្រាស់>ឯកសារ<ចំនួនពីរ>ដែល<>មិនមាននៅក្នុងបញ្ជីទេ ប៉ុន្តែ<គាត់ប្រាប់ថា គាត់>មិនមានការជំទាស់<មេធាវីក្នុងការប្រើប្រាសឯកសារ>នោះឡើយ។ ហើយខ្ញុំក៏សូមបញ្ជាក់ផងដែរថាវាជាការពិបាកក្នុងការឆ្លើយតបភ្លាមៗ ព្រោះថាក្នុងពេលកន្លងមក គឺថាយើងគ្រោងថាធ្វើម៉ោងប្រាំបួន ប៉ុន្តែយើងបានទទួលកាលពីម្សិលមិញយើងបានទទួលនៅម៉ោងប្រាំ<កន្លះ>រសៀល កាលពីម្សិល<មិញ> គឺថាគេបានមេធាវីការពារក្តីបានផ្តល់ឯកសារយ៉ាងច្រើនដែលគេត្រូវធ្វើបង្ហាញ។ ដូច្នេះ យើងដូចគ្នាគឺយើងមិនមានឱកាសទទួលបាន២៤ម៉ោង ឬក៏មិនមានឱកាសក្នុងការអានឯកសារទាំងអស់នោះទេ គឺយើង<មានឱកាសអានពីម៉ោងប្រាំកន្លះរសៀល រហូតមុនម៉ោងប្រាំបួននាព្រឹកបន្ទាប់តែប៉ុណ្ណោះ អ៊ីចឹង គ្មានអ្វីគាប់ប្រសើរ ដល់យើងទេ>។ ហើយបន្ថែមពីលើនេះទៅទៀត ប្រសិនបើជាការជួយបាន<ទៅដល់ក្រុមមេធាវីការពារក្តី ខ្ញុំនឹងរីករាយ>ផ្តល់នូវសេចក្តីព្រាងនៃឯកសារដែលខ្ញុំគ្រោង ក៏ដូចជាបញ្ជីនៃឯកសារដែលខ្ញុំគ្រោងនេះ គឺខ្ញុំបានផ្តល់ជូនដល់មេធាវី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការពារក្តីផងដែរ។ <សេចក្តីព្រាងនេះអាចជួយពួកគេនៅពេលណាមួយដែលពួកគេចង់ធ្វើការឆ្លើយតប។>

[១៥:៣៧:៤៥]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់ដោយខ្លី ពីមូលហេតុដែលថាយើងមិនអាចធ្វើការឆ្លើយតបបានភ្លាមៗនៅពេលនេះ។ ទី១ ខ្ញុំចង់បញ្ជាក់ថាឯកសារដែលព្រះរាជអាជ្ញាបានលើកអម្បាញ់មិញនេះមានចំនួន២១ឯកសារ ហើយឯកសារទាំងអស់នោះឯកសារដែលមិនស្ថិតនៅក្នុងបញ្ជីយើង យ៉ាងច្រើនហើយមានតែប្រាំឯកសារទេ យ៉ាងច្រើនដែលមាននៅក្នុងបញ្ជីរបស់យើងដែលយើងបានបង្ហាញកាលពីម្សិលមិញ។ ដូច្នេះ ឯកសារដែលលើកឡើងយ៉ាងច្រើននេះ វាទាមទារឲ្យយើងពិនិត្យទៅលើឯកសារជាក់លាក់ទាំងអស់នោះ។ ឧទាហរណ៍ព្រះរាជអាជ្ញាលើកឡើងអំពីថាលោក ខៀវ សំផន បានធ្វើដំណើរទស្សនកិច្ចជាមួយសម្តេចព្រះនរោត្តមសីហនុពាសពេញផ្ទៃប្រទេស។ បាទ នេះជាចំណុចមួយដែលយើងត្រូវពិនិត្យដែរតើអត់មានឯកសារហ្នឹងប៉ុន្មានដងដែលទៅកន្លែងណាខ្លះ ដែលថាពាសពេញផ្ទៃប្រទេសហ្នឹង វាអាចត្រឹមតែពីរដង បីដង ក៏មិនដឹងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ពីព្រោះវាមិនមានភាពជាក់លាក់ថាប៉ុន្មានដងហ្នឹង ហើយទៅកន្លែងណាខ្លះឲ្យៗច្បាស់លាស់ទេ។ ដូច្នេះ គេត្រូវការយើងពិនិត្យហើយថាតើសកម្មភាពជាក់លាក់ស្អីខ្លះនៅពេលដែលគាត់បានទៅម្តងនោះបាទ។

[១៥:៣៩:៤៥]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវី យើងគិតថា អង្គជំនុំជម្រះមានគ្រប់ទាំងទន្និករណ៍ ដើម្បីចេញសេចក្តីសម្រេចថានៅពេលណាទើបយើងទុកពេលឲ្យលោកតបឆ្លើយមកវិញ។>

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមានបំណងស្តាប់នូវមតិយោបល់របស់លោកថា តើលោកអាចឆ្លើយតបនៅពេលណា ហើយត្រូវការពេលវេលាប៉ុន្មាន? ឥឡូវនេះលោកបានបង្ហាញ -- មេធាវីការពារក្តី ខៀវ សំផន បានបង្ហាញហើយថាខ្លួនគ្មានលទ្ធភាពឆ្លើយតបទៅនឹងបណ្តាឯកសារដែលដាក់បង្ហាញដើម្បីឆ្លើយតបទៅនឹងឯកសារគន្លឹះរបស់ខ្លួនដែលបានដាក់កាលពីម្សិលមិញទេ។ ហេតុដូច្នេះអង្គជំនុំជម្រះសម្រេចថា ការឆ្លើយតបចុងក្រោយរបស់សហមេធាវីការពារក្តី ខៀវ សំផន ទៅនឹងសេចក្តីជំទាស់ទាំងឡាយរបស់

សហព្រះរាជអាជ្ញាចំពោះឯកសារគន្លឹះ ដែលបានដាក់ដោយសហមេធាវីការពារក្ដី ខៀវ សំផន នោះទៅ ថ្ងៃអង្គារ នៅក្រោយពេលដែលបញ្ចប់នូវការស្ដាប់សក្ខីកម្មអ្នកជំនាញ វឿន វុទ្ធី។

*(ចៅក្រមពិភាក្សាគ្នា)*

បាទ ច្បាស់លាស់ហើយណ៎ាអ៊ីចឹងយើងនឹងផ្ដល់ឱកាសទៅដល់ថ្ងៃ១០ ហើយគ្រប់គ្រាន់ទេ ពេលវេលាពីថ្ងៃនេះ ទៅដល់ថ្ងៃ១០ អាចឆ្លើយតបបានទេ?

[១៤:៤០:៤៧]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន នេះជាអ្វីដែលយើងយល់។ អ៊ីចឹង យើងគោរពទៅតាម<ពេលវេលាដែលអង្គជំនុំជម្រះកំណត់ឲ្យ>។ លោកប្រធានខ្ញុំមានសំណួរមួយដែរ តើយើងអាចទទួលបានការបញ្ជាក់អំពីផែនការសម្រាប់សប្ដាហ៍ក្រោយទេ លោកប្រធាន។ <ខ្ញុំសួរនេះ ដោយសារយើងដឹងថា មិនមានសាក្សីនៅថ្ងៃចន្ទទេ ហើយ>ខ្ញុំដឹងថា វឿន វុទ្ធី គឺ<មក>ថ្ងៃអង្គារព្រឹក<វិញ>។ អ៊ីចឹងមានសាក្សីផ្សេងទៀត<នៅរង់ចាំ ហើយគាត់>ប្រហែលជាត្រូវមកផ្ដល់សក្ខីកម្ម<ដែរ>។ អ៊ីចឹង សូមលោកប្រធាន មេត្តាផ្ដល់ផែនការសម្រាប់សប្ដាហ៍ក្រោយផង ដើម្បីឲ្យយើងរៀបចំខ្លួនសម្រាប់ចុងសប្ដាហ៍នេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយយើងមិនទាន់អាចឆ្លើយតបបាននៅពេលនេះទេ ដោយសារមានបញ្ហាផងដែរនៅពេលចុងបញ្ចប់នៃកិច្ចពិភាក្សាដេញដោលពិនិត្យភស្ដុតាងនេះ ហើយយើងក៏រង់ចាំនូវលទ្ធភាពនៅក្នុងការសក្ខីកម្ម ស្ដាប់សក្ខីកម្មសាក្សីចុងក្រោយតាមសំណើរបស់ភាគីផងដែរ។ ប៉ុន្តែនីតិវិធីមានស្ថានភាពស្មុគស្មាញដោយសារវាឆ្លងកាត់ប្រទេស ឆ្លងកាត់ពីរដ្ឋមួយទៅរដ្ឋមួយ ដែលមាននីតិវិធីស្មុគស្មាញ។ អ៊ីចឹងយើងនឹងជម្រាបជូនភាគីឲ្យបានជ្រាបតាមរយៈអ៊ីម៉ែលឆាប់ៗ តាមដែលអាចធ្វើទៅបាន ក្នុងករណីធ្វើទៅមិនបាននោះ ក៏ដូចគ្នាដែរ អង្គជំនុំជម្រះនឹងជម្រាបជូនដំណឹងដល់ភាគីបានជ្រាប ហើយនិងចេញសេចក្ដីសម្រេចបញ្ចប់ចុងក្រោយតែម្ដង។

បាទ ហើយសវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី0៩ ខែមករា ឆ្នាំ ២០១៧ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទ ទី0៩ ខែមករា ឆ្នាំ២០១៧ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី 2-TCW-1042 ទាក់ទងទៅនឹងទាក់ទងទៅនឹងវិធីសាស្ត្រនៃ

ការរៀបចំបញ្ជីឈ្មោះអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខស-២១។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី០៩ ខែមករា ឆ្នាំ២០១៧ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៤:៤៣ នាទី)*